# មេរៀនទី ៧៦៖ ពេត្រុសសួរសុខទុក្ខកូនេលាស

**កិច្ចការ ១០៖១-៤៨**

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/QHXL1-d692A

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/igUWT_GWCrI

**គោលបំណង៖** ព្រះទទួលយកអស់អ្នកណាដែលជឿដល់ទ្រង់។

**ខគម្ពីរចងចាំ៖** កិច្ចការ ១០៖៣៤ “ *ពេត្រុសក៏បើកមាត់និយាយថា ប្រាកដមែន ខ្ញុំយល់ឃើញ ថា ព្រះមិនរើសមុខអ្នកណាទេ ។* ”

**ចំរៀង** ( *យូធូបលីង* )៖
១.ព្រះយេស៊ូវស្រលាញ់កុមារណាស់ https://youtu.be/8iUI62Zo_Co
២. ព្រះយេស៊ូវយាងមកផ្តល់ជីវិត https://youtu.be/PXQCMUWh9RY
៣.បេសកកម្មដំណឹងល្អ https://youtu.be/T1WMFhM4Sxk

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ក្រុមឆ្កែ ក្រុមឆ្មា ក្រុមគោ ក្រុមជ្រូក»



១. ចែកកុមារជា ៤ក្រុម
២.ឲ្យក្រុមនីមួយៗ ជ្រើសរើសសត្វណាមួយតំណាងឲ្យក្រុមរបស់ពួកគេ។
៣.នៅពេលដែលគ្រូចង្អុលទៅក្រុមមួយណា ពួកគេត្រូវតែឆ្លើយតបដោយសម្លេងសត្វដែលតំណាងឲ្យក្រុមរបស់ពួកគេ។
៤.ប្រសិនបើសមាជិកក្រុមណាមួយធ្វើសម្លេងសត្វខុសក្រុមនោះនឹងចាញ់ល្បែងនេះ។
៥.( **ជម្រើស** )ក្រុមនីមួយៗ ត្រូវជ្រើសរើសមេក្រុមម្នាក់ ហើយបន្ទាប់ពីក្រុមគេធ្វើរួច ឲ្យមេក្រុមផ្សេងទៀតបន្តចង្អុលទៅក្រុមណាមួយក៏បាន។
៦.បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ទោះបីជាសត្វទាំងអស់ខុសគ្នា ហើយបញ្ចេញសំឡេងខុសគ្នាក៏ដោយ ក៏ព្រះទ្រង់ស្រឡាញ់សត្វទាំងអស់ស្មើៗគ្នា។ ដូចគ្នាដែរ ទោះជាយើងម្នាក់ៗមានលក្ខណៈខុសៗគ្នា និងនិយាយភាសាខុសគ្នាក៏ដោយ ក៏ព្រះទ្រង់ស្រឡាញ់ពួកយើងទាំងអស់គ្នាស្មើៗគ្នាដែរ។

## ៤. ការណែនាំមេរៀន

ព្រះស្រឡាញ់មនុស្សគ្រប់គ្នា ហើយព្រះចង់ឲ្យយើងគ្រប់គ្នាស្គាល់ទ្រង់។ ព្រះទទួលយកអស់អ្នកណាដែលជឿដល់ទ្រង់។ នៅពេលដែលយើងនិយាយថា “មនុស្សគ្រប់គ្នា” គឺសំដៅទៅមនុស្សទាំងអស់នៅលើពិភពលោកនេះ! ព្រះស្រឡាញ់ជនជាតិកម្ពុជា! ព្រះស្រឡាញ់ជនជាតិថៃ! ព្រះស្រឡាញ់ជនជាតិវៀតណាម! ព្រះស្រឡាញ់ជនជាតិអាហ្វ្រិក! ព្រះយេស៊ូវស្រឡាញ់មនុស្សគ្រប់គ្នាទាំងអស់។ វាជាការងារ

របស់យើងដែលត្រូវចែកចាយដំណឹងល្អពីព្រះយេស៊ូវទៅកាន់មនុស្សដទៃទៀត ដូច្នេះពួកគេអាចស្គាល់ព្រះយេស៊ូវ និងជឿលើទ្រង់។ ថ្ងៃនេះយើងនឹងរៀនពីពេត្រុសជាអ្នកដែលបានរៀនហើយដឹងថា ព្រះស្រឡាញ់មនុស្សគ្រប់គ្នាទាំងអស់ មិនមែនស្រឡាញ់តែជនជាតិអ៊ីស្រាអែលនោះទេ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវបានប្រាប់សាវករបស់ព្រះឲ្យអង្គទៅចែកចាយដំណឹងល្អអំពីទ្រង់។ ប៉ុន្តែសិស្សរបស់ព្រះអង្គខ្លះបានគិតថា ព្រះយេស៊ូវសំដៅចំពោះតែសាសន៍យូដាតែប៉ុណ្ណោះ - ប្រជាជនអ៊ីស្រាអែល។ ប្រសិនបើអ្នកជាជនជាតិយូដា ពួកគេនឹងផ្សព្វផ្សាយដល់អ្នក។ ប្រសិនបើអ្នកមិនមែនជាជនជាតិយូដាទេ ពួកគេមិនគិតថាអ្នកសំខាន់នោះទេ។ ប្រសិនបើអ្នកមិនមែនជាជនជាតិយូដាទេ ពួកគេត្រូវបានហៅថាជាសាសន៍ដទៃ ហើយជនជាតិយូដាបានគិតថា សាសន៍ដទៃមិនបរិសុទ្ធ និងមិនសំខាន់ទេ។ ជនជាតិយូដានឹងមិនបរិភោគអាហារជាមួយនឹងសាសន៍ដទៃ ឬទៅលេងផ្ទះរបស់ពួកគេឡើយ។ នោះគឺបង្ហាញពីការរើសអើង។ ប៉ុន្តែព្រះមិនពេញចិត្តនូវទង្វើរបស់ពួកគេទេ ព្រោះព្រះស្រឡាញ់មនុស្សទាំងអស់។

មានបុរសម្នាក់ឈ្មោះកូនេលាស ដែលមិនមែនជាសាសន៍យូដាទេ។ គាត់ជាសាសន៍ដទៃ ប៉ុន្តែគាត់បានជឿលើព្រះ ហើយបានអធិស្ឋានជារៀងរាល់ថ្ងៃ ដើម្បីស្វែងយល់ពីព្រះឲ្យបានច្រើនជាងមុន។ ព្រះបានឮការអធិស្ឋានរបស់គាត់ ហើយបានចាត់ពេត្រុសឱ្យទៅជួបកូនេលាស។ ប៉ុន្តែដំបូងព្រះបានមានបន្ទូលប្រាប់ពេត្រុសថា គាត់ត្រូវតែបង្រៀនអំពីព្រះយេស៊ូវដល់គ្រប់គ្នាមិនមែនតែចំពោះសាសន៍យូដាទេ។ ព្រះបានប្រាប់ពេត្រុសថា ព្រះគម្ពីរ **កិច្ចការ ១០៖១៥** "របស់អ្វីដែលព្រះបានសំអាតហើយ នោះកុំឲ្យអ្នករាប់ថាជាមិនស្អាតឡើយ"។

ដូច្នេះ ពេត្រុសបានទៅសួរសុខទុក្ខកូនេលាសនៅផ្ទះគាត់ ទោះជាគាត់ជាសាសន៍ដទៃក៏ដោយ ហើយបានប្រាប់គាត់គ្រប់យ៉ាងអំពីព្រះយេស៊ូវ។ សាសន៍ដទៃទាំងអស់ដែលនៅទីនោះបានជឿ ហើយទទួលបុណ្យជ្រមុជទឹក។ នៅទីបំផុតពេត្រុសបានយល់ថា ដំណឹងល្អគឺសម្រាប់មនុស្សគ្រប់គ្នា — មិនមែនសំរាប់តែជនជាតិយូដាទេ។ នៅក្នុងព្រះគម្ពីរ **កិច្ចការ ១០៖៣៤-៣៥** "ពេត្រុសក៏បើក មាត់និយាយថា ប្រាកដមែនខ្ញុំយល់ឃើញថា ព្រះមិនរើសមុខអ្នកណាទេ គឺនៅក្នុងគ្រប់ទាំងសាសន៍ អស់អ្នកណាដែលកោតខ្លាចដល់ទ្រង់ ព្រមទាំងប្រព្រឹត្តសេចក្តីសុចរិត នោះគាប់ដល់ព្រះហឫទ័យទ្រង់ដែរ"។

ព្រះមិនបំបែកបំបាក់មនុស្សដូចវិធីដែលមនុស្សមួយចំនួនធ្វើនោះទេ។ ទ្រង់មិនសព្វព្រះហឫទ័យទេ។ មិនថា អ្នកជាប្រុសឬស្រី ក្មេងឬចាស់ ខ្ពស់ឬទាប អ្នកមានឬក្រ ស្បែកខ្មៅឬសនោះទេ។ ទ្រង់ទទួលយកអស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់។ ព្រះប្រទានអំណោយទាននៃសេចក្តីសង្គ្រោះដល់អ្នករាល់គ្នាដែលជឿលើព្រះយេស៊ូវ! ចូរកុំបង្ហាញការបែកចែកបក្សពួកឡើយ តែសូមឲ្យចែកចាយដំណឹងល្អពីព្រះយេស៊ូវដល់អ្នករាល់គ្នាវិញ ព្រោះព្រះស្រឡាញ់មនុស្សទាំងអស់ស្មើៗគ្នា!

## ៦. សំនួរពិភាក្សា

១. តើសាសន៍យូដាហៅអ្នកដែលមិនមែនជាជនជាតិអ៊ីស្រាអែលយ៉ាងដូចម្តេច? *(សាសន៍ដទៃ)*

២.តើសាសន៍យូដាប្រព្រឹត្តយ៉ាងណាចំពោះសាសន៍ដទៃ? *(ជនជាតិយូដានឹងមិនចែករំលែកអំពីព្រះយេស៊ូវ ទេ មិនព្រមបរិភោគជាមួយនឹងពួកគេ ឬទៅលេង ផ្ទះរបស់ពួកគេទេ)*

៤. តើកូនេលាសជាសាសន៍យូដា ឬជាសាសន៍ដទៃ? *(សាសន៍ដទៃ)*

៥.តើពេត្រុសបានធ្វើអ្វីពេលគាត់ទៅលេងផ្ទះរបស់កូនេលាស? *(ពេត្រុសបានប្រាប់កូនេលាសអំពីព្រះយេស៊ូវ)*
៦. តើព្រះស្រឡាញ់អ្នកណា? *(មនុស្សទាំងអស់!)*

**៧. ល្បែងកំសាន្ត «ប៉ាវមាត់»**

១. ប្រាប់កុមារថា យើងនឹងលេងប៉ាវ " ក្តាប់ លា កន្ត្រៃ" ប៉ុន្តែដោយប្រើមាត់។

ក. ក្តាប់៖ បិតមាត់

ខ. លា៖ ហាមាត់

គ. កន្ត្រៃ៖ លៀនអណ្តាត





២.បន្ទាប់ពីណែនាំពីរបៀបលេងរួចសូមឲ្យកុមារចាប់ដៃគូរពីរៗនាក់។
៣. គូរនីមួយៗត្រូវឈរបែរខ្នងដាក់គ្នា។
៤. នៅពេលដែលគ្រូស្រែកថា "១ ២ ៣ ប៉ាវ" កុមារទាំងពីរត្រូវបែរមុខមករកគ្នា ហើយមើលថា ពួកគេធ្វើសញ្ញា ក្តាប់ លា ឬក៏កន្ត្រៃ ដោយប្រើមាត់របស់ពួកគេ។
៥. បន្តលេងល្បែងនេះ រហូតដល់ដៃគូណាមួយឈ្នះ បីដង។
៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់ដល់កុមារថា យើងត្រូវតែប្រើពាក្យសំដីរបស់យើង ដើម្បីចែកចាយដំណឹងល្អដល់ក្រុមគ្រួសារ មិត្តភ័ក្តិ ហើយសូម្បីតែមនុស្សដែលយើងមិនធ្លាប់ស្គាល់ក៏ដោយ។

**៨. ខគម្ពីរចងចាំ**

**កិច្ចការ ១០៖៣៤** " *ពេត្រុសក៏បើកមាត់និយាយថា ប្រាកដមែន ខ្ញុំយល់ឃើញ ថា ព្រះមិនរើសមុខអ្នកណាទេ* "។

**៩. ហាត្ថកម្ម៖** ឲ្យកុមារផាត់ព៌ណ " *ព្រះស្រឡាញ់មនុស្សគ្រប់គ្នាទាំងអស់*"។

**១០. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ចំណងមិត្តភាពជាមួយព្រះយេស៊ូវមិនមែនសម្រាប់តែមនុស្សពីរបីនាក់ប៉ុណ្ណោះទេ – មនុស្សទាំងអស់ទទួលបានការស្វាគមន៍។ អ្នកអាចប្រាប់អ្នកដទៃអំពីមិត្តភាពរបស់អ្នកជាមួយព្រះយេស៊ូវ ហើយផ្លាស់ប្តូរជីវិតរបស់ពួកគេ! តើអ្នកស្គាល់មនុស្សម្នាក់ដែលមានលក្ខណៈដូចកូនេលាស –មនុស្សដែលមានចម្ងល់ច្រើនអំពីព្រះដែរឬទេ? តើអ្នកអាចធ្វើដូចពេត្រុស ហើយបង្ហាញផ្លូវមនុស្សណាម្នាក់ទៅឯព្រះយេស៊ូវយ៉ាងដូចម្តេច? សរសេរឈ្មោះ "កូនេលាស" របស់អ្នកនៅលើក្រដាសបិទជិត ហើយដាក់នៅក្បែរគ្រែរបស់អ្នក។ រាល់ពេលដែលអ្នកឃើញវាសូមអធិស្ឋាន។ ត្រៀមខ្លួនដើម្បីធ្វើសកម្មភាពនៅ ពេលដែលព្រះសុំ ឱ្យអ្នកធ្វើសកម្មភាព។

# ព្រះស្រឡាញ់មនុស្សទាំងអស់!



សូមសរសេរខគម្ពីរចងចាំ: